**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមព្រះតេជៈតម្កល់លើត្បូង**

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីដ៏មហាជ័យមង្គលឧត្តុងឧត្តមប្រសើរថ្លៃថ្លា នាទិវាខួបលើកទី៧ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១១ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជវរោកាសរាជានុញ្ញាត តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ សូមសម្តែងនូវមនោសញ្ចេតនារំភើបរីករាយជាទីបំផុត និងអំណរសាទរឥតឧបមាថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីសក្ការៈ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទ្រង់គង់ព្រះបរមរាជសម្បត្តិ ដើម្បីជាម្លប់ដ៏សុខក្សេមក្សាន្ត ត្រជាក់ត្រជុំរបស់មាតុភូមិអង្គរ សម្រាប់វិបុលភាពរបស់ប្រជាជនកម្ពុជា និង ដើម្បីកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា។ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមថ្វាយព្រះពរសព្ទសាធុការបវរមហាប្រសើរបំផុតចំពោះ **ព្រះករុណាថ្លៃវិសេស** សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមរាជសម្បត្តិយូរអង្វែង មានព្រះរាជសុខភាពល្អប្រសើរបរិបូរណ៍ មានព្រះជន្មាយុយឺនយូរ មានព្រះកាយពលមាំមួន មានព្រះបញ្ញាញាណឈ្លាសវៃ និង សម្រេចបាននូវមហាជោគជ័យជានិច្ចនិរន្តរ៍ ក្នុងរជ្ជកាលដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ព្រះអង្គ ។

ក្នុងឱកាសដ៏មហាវិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុត និង ទឹកចិត្តគោរពកោតស្ញប់ស្ញែងបំផុត ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ដែលព្រះអង្គទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ និងលះបង់ព្រះកាយពលជាប្រចាំ បំពេញព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមថ្លៃថ្លា ក្នុងវិស័យសាសនា អប់រំសិក្សាធិការ សង្គមកិច្ច សុខុមាលភាព និង ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់ទិសទី បានជំរុញយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ និងកិច្ចការបរទេសនាពេលកន្លងមក ដែលញ៉ាំងឱ្យ

កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាខ្ពស់ត្រដែតនៅលើឆាកអន្តរជាតិ ។ លើសពីនេះទៅទៀត នាពេលថ្មីៗនេះ **ព្រះករុណាថ្លៃវិសេស** ទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ និង លះបង់គ្រប់បែបយ៉ាង ចំពោះសុខទុក្ខរបស់ប្រជាជនកម្ពុជា ដោយព្រះអង្គទ្រង់បានបង្កើនព្រះរាជសកម្មភាពគ្រប់ច្រកល្ហក ដើម្បីជួយដោះស្រាយទុក្ខលំបាកជាប្រចាំរបស់ប្រជាជន ជាពិសេស ប្រជាជនដែលទទួលរងគ្រោះដោយសារទឹកជំនន់ ។

ដើម្បីស័ក្តិសមទៅនឹងព្រះគុណូបការៈដ៏មហាធំធេងនេះ របស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាចិត្តបំពេញភារកិច្ចរបស់ទូលព្រះបង្គំយើងខ្ញុំ តាមមុខសញ្ញារៀងៗខ្លួន ដោយប្រកាន់ខ្ជាប់នូវសីលធម៌ស្អាតស្អំ អភិបាលកិច្ចល្អ និង ដោយធ្វើឱ្យមានជាប្រចាំនូវប្រសិទ្ធភាព និង ប្រសិទ្ធផលការងារ ដើម្បីដង្ហែតាមព្រះរាជកិច្ច និង ព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាថ្លៃវិសេស** ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ប្រយោជន៍សម្រាប់វិបុលសុខ សុខុមាលភាពរបស់ប្រជាជនកម្ពុជា និង ភាពរុងរឿង និង កិត្យានុភាពខ្ពស់ត្រដែតនៃព្រះរាជាណាចក្រកម្ពុជា ។

ជាមួយព្រះពរសព្ទសាធុការមហាប្រសើរ និង ការថ្វាយមហាករុណាទីយគុណនេះ ទូលព្រះបង្គំយើងខ្ញុំ សូម **ព្រះករុណាថ្លៃវិសេស** ព្រះអង្គទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងមនោសញ្ចេតនាគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត និង ភក្តីភាពឥតងាករេរបស់ ទូលព្រះបង្គំយើងខ្ញុំ

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**